ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ : ២១៥ ប្រក. បស្ត

# ប្រកាស

# ស្តីពី

# ការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ ៣៤៦ ប្រក.សសរ.បស្ត ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ ៣៧៦ ប្រក.បស្ត ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១**.-

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌនៃការចុះបញ្ជី និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

**ប្រការ២**.-

ក្រុមហ៊ុនទីប្រឹក្សាដែលមានបំណងធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន។

ក្រុមហ៊ុនទីប្រឹក្សាទាំងឡាយណាដែលមិនបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន មិនអាចធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបានឡើយ។

**ប្រការ៣**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ពាក្យស្នើសុំ ០៣ច្បាប់
- លិខិតចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ០៣ច្បាប់
- លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុនដោយអាជ្ញាធរមូលដ្ឋាន ០៣ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន ០៣ច្បាប់
- វេចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ០៣ច្បាប់
- សាវតាក្រុមហ៊ុន ០៣ច្បាប់
- ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ផ្សេងៗ

**ប្រការ៤**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវមាននាយកក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងជំនួយការបច្ចេកទេស។ ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពទាំងនេះ ក្រុមហ៊ុនទីប្រឹក្សាត្រូវជូនដំណឹងមកក្រសួងបរិស្ថាន ត្រឹមរយៈពេលយ៉ាងយូរបំផុតត្រឹម ៣០(សាមសិប)ថ្ងៃ។

**ប្រការ៥**.-

នាយកក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
- មានបទពិសោធន៍ក្នុងការគ្រប់គ្រងទូទៅ ឬបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម យ៉ាងតិច ០៥(ប្រាំ)ឆ្នាំ និងធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។



ន៍

**ប្រការ៦.-**

ប្រធានក្រុមបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់សមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់ ។ល។

**ប្រការ៧.-**

អ្នកជំនាញការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៣(បី)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៣(បី)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់ ។ល។

**ប្រការ៨.-**

អ្នកជំនួយការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបរិស្ថានយ៉ាងតិច ០១(មួយ)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានការយល់ដឹងទូទៅស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បទដ្ឋានច្បាប់ និងបច្ចេកទេសនានាពាក់ព័ន្ធនឹងបរិស្ថាន។

**ប្រការ៩.-**

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបង់ថ្លៃសេវាចុះបញ្ជីដល់ក្រសួងបរិស្ថាន។ ថ្លៃសេវានេះ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០.-**

ក្រសួងបរិស្ថានផ្តល់វិញ្ញាបនបត្រទទួលស្គាល់ ដែលមានសុពលភាពសម្រាប់រយៈពេល ០៥(ប្រាំ)ឆ្នាំ ដល់ក្រុមហ៊ុនទីប្រឹក្សា ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ៣ ដល់ប្រការ៩ នៃប្រកាសនេះ។

**ប្រការ១១.-**

ក្រុមហ៊ុនទីប្រឹក្សាបរទេស ត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាក្នុងស្រុកដែលបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។



ទ

**ប្រការ១២**.-

ក្រុមហ៊ុនទីប្រឹក្សា ដែលមានបំណងបន្តផ្តល់សេវាសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់សារជាថ្មី មកក្រសួងបរិស្ថានយ៉ាងតិចបំផុតរយៈពេល ០៣ (បី) ខែ មុនថ្ងៃអស់សុពលភាពនៃវិញ្ញាបនបត្រនេះ។

**ប្រការ១៣**.-

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិស្តីពីគោលការណ៍ណែនាំក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ព្រមទាំងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។

**ប្រការ១៤**.-

វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានព្យួរពីរយៈពេល ០៦ (ប្រាំមួយ) ខែ ដល់ ០៣ (បី) ឆ្នាំ ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនមានកំហុសដោយការធ្វេសប្រហែសនៅក្នុងការចុះសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ក្រុមហ៊ុនបានចម្លងទិន្នន័យពីឯកសារ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមផ្សេងៗ ដោយគ្មានឯកសារយោង
- ក្រុមហ៊ុនខកខានមិនបានជូនដំណឹងមកក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ៤។

**ប្រការ១៥**.-

វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានលុបចោល ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនទីប្រឹក្សានៅតែបំពានលក្ខខណ្ឌចែងក្នុងប្រការ១៤
- ក្រុមហ៊ុនមានកំហុសចេតនាដោយមិនបង្ហាញពីហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានតាមលទ្ធផលជាក់ស្តែងនៃការសិក្សា
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គ្មានគុណភាព និង/ឬមានការភូតកុហកក្លែងបន្លំធ្ងន់ធ្ងរ ដែលបណ្តាលឱ្យខូចខាតដល់ផលប្រយោជន៍ជាតិ
- ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ។

**ប្រការ១៦**.-

ក្រុមហ៊ុនទីប្រឹក្សាមិនអាចដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ឡើងវិញ ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីវិញ្ញាបនបត្រទទួលស្គាល់ត្រូវបានលុបចោល។

**ប្រការ១៧**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ លើការសិក្សា និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**ប្រការ១៨**.-

ក្រុមហ៊ុនទីប្រឹក្សា ដែលបានចុះបញ្ជីមុនការចូលជាធរមាននៃប្រកាសនេះ ត្រូវដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ឡើងវិញមកក្រសួងបរិស្ថាន។



ស

ក្នុងករណីដែលវិញ្ញាបនបត្រទទួលស្គាល់ឡើងវិញមិនត្រូវបានផ្តល់ជូន ក្រុមហ៊ុនទីប្រឹក្សាក្នុងកថាខណ្ឌខាងលើ មានរយៈពេល១២ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃប្រកាសនេះ ដើម្បីបញ្ចប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលនៅសេសសល់។

**ប្រការ ១៩**.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០**.-

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង អគ្គាធិការ នាយកខុទ្ទកាល័យរដ្ឋមន្ត្រី ប្រធានក្រុមការងារបច្ចេកទេសពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធាននាយកដ្ឋាន និងប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ